COPY

# ផែនការសហប្រតិបត្តិការ ឆ្នាំ២០១១

## រវាង

## ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា

## និង

## ក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម (ខាងក្រោមនេះហៅកាត់ថាភាគីទាំងពីរ) ៖

-យោងកិច្ចព្រមព្រៀងសហប្រតិបត្តិការ បង្ការ ប្រឆាំងឧក្រិដ្ឋកម្ម រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម (បច្ចុប្បន្នជាក្រសួងនគរបាល) ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៧ នៅភ្នំពេញ។

-យោងទិសដៅសហប្រតិបត្តិការ ៥យ៉ាង ដែលថ្នាក់ដឹកនាំក្រសួងទាំងពីរ បានព្រមព្រៀងគ្នាក្នុងដំណើរទស្សនកិច្ចផ្លូវការជាមិត្តភាពនៅវៀតណាម របស់គណៈប្រតិភូជាន់ខ្ពស់ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្ងៃទី ០៦-០៩ ខែកក្កដា ឆ្នាំ២០០០។

ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ ៖

## I. កិច្ចសហប្រតិបត្តិការការពារសន្តិសុខជាតិ កសាងខ្សែបន្ទាត់ព្រំដែនសន្តិភាព មិត្តភាព ស្ថេរភាព និងអភិវឌ្ឍ :

១-ភាគីទាំងពីរត្រូវជូនដំណឹងអោយគ្នាជាប្រចាំ និងទាន់ពេលវេលា អំពីសភាពការណ៍ ពត៌មានស្តីពីឧបាយកល ល្បិចកល និងសកម្មភាពរបស់បណ្តាអនុភាពអមិត្តដែលតែងតែមានបំណងបំផ្លិចបំផ្លាញចំណងសាមគ្គីភាព មិត្តភាពជាប្រពៃណីរវាងប្រជាជាតិទាំងពីរ បង្កមហន្តរាយដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ស្ថេរភាព និងការអភិវឌ្ឍ នៃប្រទេសនីមួយៗ។

២-ភាគីទាំងពីរត្រូវរួមសហការអោយបានជិតស្និទ្ធ និងដាក់ចេញនូវវិធានការជាក់ស្តែង ដើម្បីតស៊ូប្រកបដោយប្រសិទ្ធិភាពប្រឆាំងរាល់ឧបាយកល ល្បិចកល សកម្មភាពរបស់បណ្តាអានុភាពអមិត្តទាំងក្នុង និងក្រៅប្រទេស ជាពិសេសការប្រើប្រាស់ជនជាតិខ្មែរល្មើសច្បាប់ ឬ ពួកប្រតិកិរិយានិរទេសជាជនជាតិវៀតណាមពីប្រទេសទីបី ដោយប្រើប្រាស់ភូមិសាស្ត្រកម្ពុជា និងវៀតណាម ដើម្បីធ្វើសកម្មភាពបំផ្លិចបំផ្លាញ ឬ ភេរវកម្ម បង្កអស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមរបស់ប្រទេសនីមួយៗ។

៣_ក្នុងករណីកើតមានហេតុការណ៍ពាក់ព័ន្ធដល់សន្តិសុខជាតិ នៃប្រទេសនីមួយៗ ពេលភាគីម្ខាងមានសំណូមពរ ភាគីម្ខាងទៀតត្រូវខិតខំឆ្លើយតបតាមលទ្ធភាពដោយស្របទៅតាមច្បាប់ នៃប្រទេសខ្លួន និងបណ្តាបទដ្ឋានជាអន្តរជាតិដែលបានចុះហត្ថលេខា ដើម្បីជួយដោះស្រាយហេតុការណ៍នោះអោយបានចាប់រហ័ស ។

៤_ពេលរកឃើញរាល់បាតុភាពដែលពាក់ព័ន្ធដល់បញ្ហាព្រំដែនរបស់ប្រទេសទាំងពីរ ភាគីទាំងពីរត្រូវរួមសហការគ្នាយ៉ាងជិតស្និទ្ធ និងដោះស្រាយអោយបានទាន់ពេលតាមរយៈការទូត ឈរលើស្មារតីសន្តិភាព សហប្រតិបត្តិការ ជាមិត្តភាពដោយមិនទុកឱ្យមានការអូសបន្លាយដែលបង្កអោយមានភាពស្មុគស្មាញបន្ថែមទៀត។ ភាគីទាំងពីរត្រូវមានផែនការជាក់ស្តែង ដើម្បីរួមចំណែកធានាសន្តិសុខបំរើឱ្យផែនការកំណត់ខ័ណ្ឌសីមា និងការបោះបង្គោលព្រំដែនគោក សំរេចអោយបានតាមផែនការរបស់រដ្ឋាភិបាលទាំងពីរ។ ភាគីទាំងពីរបន្តជំរុញការផ្សព្វផ្សាយ និងអប់រំប្រជាពលរដ្ឋអោយគោរពប្រតិបត្តិបទបញ្ញត្តិព្រំដែន និងចូលរួមការពាររក្សាសន្តិសុខ សណ្តាប់ធ្នាប់ព្រំដែន។

៥_ក្នុងឆ្នាំ២០១១ និងបណ្តាឆ្នាំ បន្តភាគីទាំងពីររួមសហការជាមួយក្រសួងសន្តិសុខសាធារណៈឡាវ រៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី រវាងប្រទេសទាំងបី ដើម្បីផ្លាស់ប្តូរ និងឯកភាពបណ្តាវិធានការសហប្រតិបត្តិការ ការពារសន្តិសុខ និងសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម ពិសេសក្នុងតំបន់ត្រីកោណអភិវឌ្ឍ សំដៅរួមចំណែកអនុវត្តសេចក្តីប្រកាសភ្នំពេញ ស្តីពីការពង្រឹងតំបន់ត្រីកោណអភិវឌ្ឍ កម្ពុជា ឡាវ វៀតណាម ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១០។

៦_ភាគីទាំងពីរសហការជួយឧបត្ថម្ភគាំទ្រគ្នាទៅវិញទៅមក ក្នុងការអនុវត្តន៍គោលការណ៍សហគមន៍នយោបាយ_សន្តិសុខអាស៊ាន។

II. <u>កិច្ចសហប្រតិបត្តិការ បង្ការ ប្រឆាំងឧក្រិដ្ឋកម្ម រក្សាសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម</u> :

១_ភាគីទាំងពីរត្រូវជូនដំណឹង និងធ្វើការផ្លាស់ប្តូរអោយគ្នាជាប្រចាំ និងទាន់ពេលវេលា អំពីពត៌មានឯកសារ និងពិភាក្សាវិធានការរួមសហការតស៊ូ បង្ការ ប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនមានអង្គការចាត់តាំងពាក់ព័ន្ធដល់ប្រទេសទាំងពីរដូចជា ភេរវកម្មអន្តរជាតិ ការចរាចរណ៍ ការជួញដូរ និងដឹកជញ្ជូនគ្រឿងញៀន ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ការផលិត និងចរាចរលុយក្លែងក្លាយ សកម្មភាពលាងលុយ ការជួញដូរ និងដឹកជញ្ជូនបណ្តាមុខទំនិញហាមឃាត់ ការរត់ពន្ធ ការក្លែងបន្លំរបរជំនួញ អន្តោប្រវេសន៍ខុសច្បាប់ និងបណ្តាបទឧក្រិដ្ឋផ្សេងទៀត ។

២_ករណីមានឧក្រិដ្ឋជនរត់គេចខ្លួនពីប្រទេសម្ខាងទៅប្រទេសម្ខាងទៀត ភាគីទាំងពីរត្រូវជូនដំណឹងអោយគ្នាបានជ្រាបទាន់ពេលជាលាយល័ក្ខអក្សរ ដើម្បីមានវិធានការរួមសហការ និងចង្អុលដឹកនាំបណ្តាអង្គភាពពាក់ព័ន្ធតាមរកចាប់ឃាត់ខ្លួន និងបំពេញសំណុំបែបបទប្រគល់ បញ្ជូនមនុស្ស និងវត្ថុតាងឱ្យគ្នា ស្របទៅតាមច្បាប់របស់ប្រទេសនីមួយៗ។

៣-ភាគីទាំងពីរអះអាងបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់កំណត់ហេតុប្រជុំទ្វេភាគីលើកទី ១០ ស្តីពីសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន សារធាតុប៉ះពាល់សរសៃប្រសាទ និងសារធាតុគីមីផ្សំ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០ នៅរាជធានីភ្នំពេញ រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មាធិការត្រួតពិនិត្យជំងឺអេដស៍ គ្រឿងញៀន និងពេស្យាចារ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

៤-ភាគីទាំងពីររួមសហការឧបត្ថម្ភ និងជួយគ្នាទៅវិញទៅមកក្នុងសកម្មភាពរបស់អង្គការ ASEANAPOL INTERPOL និងបណ្តាអង្គការថ្នាក់តំបន់ អន្តរជាតិផ្សេងទៀតដែលភាគីទាំងពីរចូលរួម ។

៥-ភាគីទាំងពីររួមសហការបង្កលក្ខណៈងាយស្រួល និងការពារសុវត្ថិភាពជូនបណ្តាគណៈប្រតិភូ នៃប្រទេសទាំងពីរនៅពេលបំពេញទស្សនកិច្ច ចូលរួមសន្និសីទ សិក្ខាសាលាអន្តរជាតិ ទំនាក់ទំនងផ្លាស់ប្តូរវប្បធម៌ កីឡាពិពណ៌ ការធ្វើទេសចរណ៍ និងពលរដ្ឋ នៃប្រទេសម្ខាងដែលស្នាក់នៅ បំពេញការងារ រៀនសូត្រ សួរសុខទុក្ខញាតិសណ្តាន ព្យាបាលជម្ងឺនៅប្រទេសម្ខាងទៀត។

## III. <u>កិច្ចសហប្រតិបត្តិការផ្លាស់ប្តូរគណៈប្រតិភូទៅបំពេញទស្សនកិច្ចការងារ ពិនិត្យព្យាបាលជម្ងឺ</u> :

ក-ក្រសួងមហាផ្ទៃកម្ពុជាចាត់បញ្ជូន ក្រសួងនគរបាលវៀតណាមទទួល :

១-គណៈប្រតិភូជាន់ខ្ពស់ ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជាអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការដើម្បីវាយតម្លៃពីលទ្ធផល នៃកិច្ចសហប្រតិបត្តិការឆ្នាំ ២០១១ និងចុះហត្ថលេខាលើផែនការសហប្រតិបត្តិការឆ្នាំ ២០១២ រវាងក្រសួងទាំងពីរ។

២-គណៈប្រតិភូនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចចំនួន ០៥រូប អញ្ជើញទៅបំពេញទស្សនកិច្ចដកពិសោធន៍ការងារប្រយុទ្ធប្រឆាំងបទល្មើសសេដ្ឋកិច្ចរយៈពេល ០៥ថ្ងៃ នៅចុងត្រីមាសទី I ឆ្នាំ២០១១។

៣-គណៈប្រតិភូនាយកដ្ឋាននគរបាលព្រហ្មទណ្ឌចំនួន ០៥រូប អញ្ជើញទៅបំពេញទស្សនកិច្ចដកពិសោធន៍ការងារតាមប្រមាញ់មុខសញ្ញាបួនរយៈពេល ០៥ថ្ងៃ នៅចុងត្រីមាសទី III ឆ្នាំ២០១១។

៤-គណៈប្រតិភូ នៃអគ្គនាយកដ្ឋានពន្ធនាគារចំនួន ០៧រូប អញ្ជើញទៅបំពេញទស្សនកិច្ច និងពិភាក្សាផែនការសហប្រតិបត្តិការជួយឧបត្ថម្ភគ្នា រវាងអគ្គនាយកដ្ឋានពន្ធនាគារ និងអគ្គនាយកដ្ឋានតំរួតអនុវត្តសាលក្រមព្រហ្មទណ្ឌ និងជំនួយផ្នែកច្បាប់រយៈពេល ០៥ថ្ងៃ នៅក្នុងត្រីមាសទី III ឆ្នាំ២០១១។

៥-ក្នុងឆ្នាំ ២០១១ ក្រសួងនគរបាលវៀតណាមនឹងជួយឧបត្ថម្ភក្នុងការពិនិត្យព្យាបាលជម្ងឺជូនមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃកម្ពុជាចំនួន ៣០រូប ក្នុង០១លើកចំនួន ១៥រូប រយៈពេលពី ០៧-១០ថ្ងៃ នៅមន្ទីរពេទ្យក្រសួងនគរបាលវៀតណាម។ ក្នុងករណីវិសមញ្ញចាំបាច់ ក្រសួងមហាផ្ទៃកម្ពុជានឹងមានលិខិតស្នើជាក់ស្តែង ហើយក្រសួងនគរបាលវៀតណាមត្រៀមខ្លួនឆ្លើយតប។

៦_គណៈប្រតិភូក្រុមការងារក្រសួងមហាផ្ទៃកម្ពុជា អញ្ជើញទៅបំពេញទស្សនកិច្ចការងារ ដើម្បីផ្លាស់ប្តូរលទ្ធផលសហប្រតិបត្តិការ ឆ្នាំ២០១១ និងត្រៀមខ្លឹមសារផែនការសហប្រតិបត្តិការ ឆ្នាំ២០១២ រយៈពេល ០៥ថ្ងៃ នៅចុងត្រីមាសទី IV ឆ្នាំ២០១១។

**ខ-ក្រសួងនគរបាលវៀតណាមចាត់បញ្ជូន ក្រសួងមហាផ្ទៃកម្ពុជាទទួល :**

១_គណៈប្រតិភូជាន់ខ្ពស់ក្រសួងនគរបាលវៀតណាមអញ្ជើញមកបំពេញទស្សនកិច្ច និងចុះហត្ថលេខាលើផែនការសហប្រតិបត្តិការឆ្នាំ ២០១១ រវាងក្រសួងទាំងពីរ រយៈពេល ០៣ថ្ងៃ ត្រីមាសទី I ឆ្នាំ ២០១១។

២_គណៈប្រតិភូ នៃអគ្គនាយកដ្ឋានសន្តិសុខក្រៅប្រទេសចំនួន ០៥រូប អញ្ជើញមកផ្លាស់ប្តូរបទពិសោធន៍អំពីការងារតស៊ូ ចំពោះមុខសញ្ញាប្រតិកិរិយានីរទេសដែលប្រើប្រាស់ភូមិសាស្ត្រ ដើម្បីធ្វើសកម្មភាពភេរវកម្ម បទល្មើសឆ្លងដែន រយៈពេល ០៥ថ្ងៃ ក្នុងត្រីមាសទី II ឆ្នាំ២០១១។

៣_គណៈប្រតិភូ នៃអគ្គនាយកដ្ឋានសន្តិសុខក្នុងប្រទេសចំនួន ០៥រូប អញ្ជើញមកផ្លាស់ប្តូរបទពិសោធន៍អំពីការងារតស៊ូប្រឆាំងពួកប្រតិកិរិយាដែលឆ្លៀតប្រើប្រាស់ជនជាតិ សាសនា រយៈពេល ០៥ថ្ងៃ ក្នុងត្រីមាសទី III ឆ្នាំ ២០១១។

៤_គណៈប្រតិភូ នៃអគ្គនាយកដ្ឋានចារកម្មចំនួន ០៥រូប អញ្ជើញមកបំពេញទស្សនកិច្ចការងារ រយៈពេល ០៥ថ្ងៃ ក្នុងត្រីមាសទី IV ឆ្នាំ២០១១។

៥_គណៈប្រតិភូនគរបាលចំនួន ៦០រូប ចាប់ពីថ្នាក់ស្នងការរងខេត្ត ថ្នាក់អនុប្រធាននាយកដ្ឋានឡើងទៅរបស់ក្រសួងនគរបាលវៀតណាម អញ្ជើញធ្វើទស្សនកិច្ចសំរាកលំហែនៅកម្ពុជា ដោយចែកចេញជាពីរវគ្គ មួយវគ្គៗមានចំនួន ៣០រូប រយៈពេល ០៧ថ្ងៃ:

-វគ្គទី ១ ប្រព្រឹត្តទៅនាខែវិច្ឆិកា ឆ្នាំ២០១១

-វគ្គទី ២ ប្រព្រឹត្តទៅនាខែធ្នូ ឆ្នាំ២០១១

**គ-ការផ្លាស់ប្តូរគណៈប្រតិភូ ឬក្រុមការងារជំនាញក្រៅការគ្រោងទុក :**

ក្នុងករណីបណ្តាអង្គភាពឯកទេសរបស់ភាគីទាំងពីរមានសំណូមពរ អញ្ជើញ ឬចាត់បញ្ជូនមន្ត្រី ឬក្រុមការងារដើម្បីធ្វើការសិក្សាប្រឹក្សាយោបល់លើផ្នែកបច្ចេកទេសនោះ ការចាត់អញ្ជើញ ឬចាត់បញ្ជូនមន្ត្រី ឬក្រុមការងារត្រូវមានការយល់ព្រមពីថ្នាក់មានសមត្ថកិច្ចរបស់ភាគីនីមួយៗ ហើយត្រូវជូនដំណឹងឱ្យគ្នាជាលាយលក្ខណ៍អក្សរតាមរយៈអង្គភាពទំនាក់ទំនងអន្តរជាតិ នៃភាគីទាំងពីរ។

## IV. <u>កិច្ចសហប្រតិបត្តិការបណ្តុះបណ្តាល បំពាក់បំប៉នមន្ត្រី</u> :

ភាគីទាំងពីរឯកភាពប្រគល់អោយបណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងបណ្ឌិត្យសភាតម្រួតប្រជាជន ក្រសួងនគរបាលវៀតណាម បន្តការជួយឧបត្ថម្ភគ្នាទៅវិញទៅមកតាមផែនការដែលថ្នាក់ដឹកនាំក្រសួងទាំងពីរបានសំរេច និងកំណត់ហេតុដែលបណ្ឌិត្យសភាទាំងពីរបានចុះហត្ថលេខាកាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៨ នៅហាណូយ។

ក-ក្រសួងនគរបាលវៀតណាមត្រៀមចាត់បញ្ជូនគ្រូបង្រៀនចំនួន ១០រូប មកកម្ពុជាដោយប្តូរវេន ០១ខែ ឬយូរ ដើម្បីជួយបើកវគ្គបណ្តុះបណ្តាលបំពាក់បំប៉នមន្ត្រីតាមបណ្តាឯកទេសជំនាញដូចតទៅ :

១- គ្រូជំនាញវៀតណាមចំនួន ០៤រូប មកបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិ លើវគ្គសិក្សាជំនាញវិទ្យុទាក់ទង (ថ្នាក់បឋមបច្ចេកទេស) រយៈពេល ០៦ខែ ដែលនឹងប្រព្រឹត្តិទៅនៅខែមិថុនា ឆ្នាំ ២០១១។

២-គ្រូជំនាញវៀតណាមចំនួន ០៣រូប មកបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិ លើវគ្គសិក្សាបំប៉នជំនាញស្រាវជ្រាវសួរចំលើយផ្នែកសន្តិសុខ រយៈពេល ០៣ខែ ដែលនឹងប្រព្រឹត្តិទៅនាខែសីហា ឆ្នាំ ២០១១។

៣-គ្រូជំនាញវៀណាមចំនួន ០៣រូប មកបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិ លើវគ្គសិក្សាបំប៉នជំនាញគ្រប់គ្រងសណ្តាប់ ធ្នាប់សុវត្ថិភាពចរាចរ រយៈពេល ០៣ខែ ដែលនឹងប្រព្រឹត្តិទៅនាខែសីហា ឆ្នាំ២០១១។

ខ-ក្រសួងនគរបាលវៀតណាមត្រៀមចាត់អ្នកជំនាញឯកទេសមកជួយបំពាក់បំប៉ន លើការងារតស៊ូករណីជំនាញ (ចំនួនអ្នកជំនាញឯកទេស រយៈពេល និងកាលបរិច្ឆេទហ្វឹកហាត់ ភាគីកម្ពុជានឹងផ្ញើលិខិតផ្លូវការស្នើទៅភាគីវៀតណាមនៅពេលមានតំរូវការជាក់ស្តែង)។

គ-ក្រសួងនគរបាលវៀតណាមបន្តទទួលមន្ត្រីរបស់ក្រសួងមហាផ្ទៃកម្ពុជា ចំនួន ៣៥០រូប ដើម្បីបណ្តុះបណ្តាល និងបំពាក់បំប៉នជំនាញនៅវៀតណាម តាមបណ្តាឯកទេសជំនាញដូចតទៅ :

១.បណ្តុះបណ្តាលរយៈពេលវែងចំនួន **៣០រូប :**

-មន្ត្រីនគរបាលជាតិកម្ពុជាចំនួន ១៥រូប ទៅសិក្សាជំនាញវិទ្យុទាក់ទង ថ្នាក់មហាវិទ្យាល័យ រយៈពេល ០៥ឆ្នាំ ក្នុងនោះសិក្សាភាសា ០១ឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំសិក្សា ២០១១-២០១២។

-មន្ត្រី នៃអគ្គនាយកដ្ឋានពន្ធនាគារចំនួន ១៥រូប ទៅបណ្តុះបណ្តាលឯកទេសពន្ធនាគារ ថ្នាក់មហាវិទ្យាល័យ រយៈពេល ០៦ឆ្នាំ (សិក្សាភាសា ០១ឆ្នាំ) ចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០១១ នៅភាគខាងជើង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

២.បំប៉នរយៈពេលខ្លីចំនួន **៣២០រូប :**

-នាយនគរបាលជាតិជាន់ខ្ពស់ចំនួន ៦០រូប (អ្នកបកប្រែចំនួន ០៤រូប) ដោយចែកចេញជា ០២វគ្គ ក្នុងមួយវគ្គមានចំនួន ៣០រូប (អ្នកបកប្រែចំនួន ០២រូប) ទៅចូលរួមវគ្គបំប៉នជំនាញការងារដឹកនាំថ្នាក់នាយកដ្ឋាន-ស្នងការ និងថ្នាក់ការិយាល័យលើកទី ២២ និងលើកទី ២៣ រយៈពេល ០៣ខែ នៅសាលាមធ្យមសិក្សាសន្តិសុខប្រជាជន II ភាគខាងត្បូង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ៖

+វគ្គលើកទី ២២: ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១១

+វគ្គលើកទី ២៣: ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០១១

-នាយនគរបាលជាតិចំនួន ៦០រូប (អ្នកបកប្រែចំនួន ០៤រូប) ដោយចែកចេញជា ០២វគ្គ ក្នុងមួយវគ្គមានចំនួន ៣០រូប (រួមអ្នកបកប្រែចំនួន ០២រូប) ទៅចូលរួមវគ្គបំប៉នជំនាញ ការងារដឹកនាំថ្នាក់អធិការនគរបាល ក្រុង-

ស្រុក-ខណ្ឌ លើកទី ១៣ និងលើកទី ១៤ រយៈពេល ០៣ខែ នៅសាលាមធ្យមសិក្សាសន្តិសុខប្រជាជន II ភាគខាងត្បូង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ៖

+វគ្គលើកទី ១៣ : ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១១

+វគ្គលើកទី ១៤ : ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១១

-នាយនគរបាលជាតិចំនួន ៣០រូប (អ្នកបកប្រែចំនួន ០២រូប) ទៅចូលរួមវគ្គបំប៉នជំនាញការការពារថ្នាក់ដឹកនាំជាន់ខ្ពស់ រយៈពេល ០៣ខែ ដែលនឹងបើកវគ្គនាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ នៅភាគខាងត្បូង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-នាយនគរបាលជាតិ ចំនួន ២៥រូប (អ្នកបកប្រែចំនួន ០២រូប) ទៅចូលរួមវគ្គបំប៉នជំនាញការការពារគោលដៅ រយៈពេល ០៣ខែ ដែលនឹងបើកវគ្គនាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ នៅភាគខាងជើង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-មន្ត្រីនគរបាលជាតិ ចំនួន ២០រូប (អ្នកបកប្រែចំនួន ០២រូប) ទៅចូលរួមវគ្គបំប៉នជំនាញស្រាវជ្រាវបង្ក្រាបបទឧក្រិដ្ឋ រយៈពេល ០៣ខែ ចាប់ផ្តើមប្រព្រឹត្តិទៅនាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ នៅភាគខាងជើង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-នាយនគរបាលជាតិ ចំនួន ១៥រូប (អ្នកបកប្រែចំនួន ០១រូប) ទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញហ្វឹកហ្វឺនប្រឆាំងអំពើភេរវកម្ម រយៈពេល ០៣ខែ ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១១ នៅភាគខាងជើង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-នាយនគរបាលជាតិ ចំនួន ៣០រូប (អ្នកបកប្រែចំនួន ០១រូប) ទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញហ្វឹកហ្វឺនកងកំលាំងពិសេស រយៈពេល ០៣ខែ ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ នៅភាគខាងជើង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-មន្ត្រីនគរបាលជាតិ ចំនួន ២០រូប (អ្នកបកប្រែចំនួន ០១រូប) ទៅចូលរួមវគ្គបំប៉នជំនាញស្រាវជ្រាវបទល្មើសសេដ្ឋកិច្ច រយៈពេល ០៣ខែ ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ នៅភាគខាងជើង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-មន្ត្រីនគរបាលជាតិ ចំនួន ៣០រូប (អ្នកបកប្រែចំនួន ០១រូប) ទៅចូលរួមវគ្គបំប៉នជំនាញស្រាវជ្រាវពិនិត្យនិងវិភាគកន្លែងកើតហេតុ រយៈពេល ០៣ខែ ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០១១ នៅភាគខាងជើង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

-មន្ត្រីចំនួន ៣០រូប មកពីបញ្ជាការដ្ឋានអង្គរក្ស នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ (អ្នកបកប្រែ ០១រូប) ទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញការពារថ្នាក់ដឹកនាំជាន់ខ្ពស់ រយៈពេលពេល ០៣ខែ ដោយចាប់ផ្តើមពីខែ មិថុនា ឆ្នាំ ២០១១ នៅភាគខាងត្បូង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

V. **កិច្ចសហប្រតិបត្តិការវិស័យភស្តុភារ សំភារៈបច្ចេកទេស :**

១. ភាគីទាំងពីរឯកភាពជំរុញឱ្យមានកិច្ចសហប្រតិបត្តិការលើវិស័យភស្តុភារ សំភារៈបច្ចេកទេស។

២. ក្នុងឆ្នាំ២០១១ ក្រសួងនគរបាលវៀតណាមនឹងជួយដល់ក្រសួងមហាផ្ទៃកម្ពុជា ជាក់ស្តែងដូចខាងក្រោម៖

_បន្តបំពាក់នូវប្រព័ន្ធវិទ្យុទាក់ទងសំរាប់វរៈសេនាតូចការពារព្រំដែនលេខ ១០៥ របស់ក្រសួងមហាផ្ទៃកម្ពុជា។

_តាមសំណើររបស់ក្រសួងមហាផ្ទៃកម្ពុជា ក្រសួងនគរបាលវៀតណាមយល់ព្រមពិនិត្យ និងបំពាក់នូវប្រព័ន្ធសោទស្សន៍ (កាមេរ៉ា ត្រួតពិនិត្យ) បំរើការងារសន្តិសុខ សណ្តាប់ធ្នាប់ នៅគោលដៅសំខាន់ៗមួយចំនួន។

_តាមសំណើររបស់ក្រសួងមហាផ្ទៃកម្ពុជា តាមរយៈលិខិតលេខ ១៨៣ ស.ជ.ណ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១០ ក្រសួងនគរបាលវៀតណាម យល់ព្រមបំពាក់ជូនកងកម្លាំងនគរបាលជាតិកម្ពុជា នូវឯកសណ្ឋានគំរូតពិសេស ចំនួន ៣,២០០កំប្លេ និងសំភារៈចំនួន ០៦ ប្រភេទផ្សេងទៀត ដូចមានបញ្ជីរាយមុខសំភារៈភ្ជាប់ជាមួយ។

ភាគីទាំងពីរ ប្រគល់ឱ្យអង្គភាពទំនាក់ទំនងអន្តរជាតិរបស់ខ្លួន សហការជាមួយបណ្តាអង្គភាពពាក់ព័ន្ធដើម្បីម្ចាស់ការផ្តើមស្នើលើកផែនការចាត់តាំងអនុវត្តនូវខ្លឹមសារជាក់ស្តែងដូចមានចែងខាងលើ។

VI. **យន្តការសហប្រតិបត្តិការ :**

១_ការផ្លាស់ប្តូរពត៌មាន ឯកសារ ក្នុងក្របខ័ណ្ឌផែនការសហប្រតិបត្តិការនេះ ត្រូវដំណើរការជាលាយលក្ខអក្សរ ជានាសំងាត់ និងមិនប្រគល់អោយទៅភាគីទី ៣ ប្រសិនបើគ្មានការយល់ព្រមជាមុនដោយលាយលក្ខអក្សរពីភាគីប្រគល់ទេនោះ និងឆ្លងតាមរយៈបណ្តាញ៖

_ការបរទេស (ស្ថានទូត ស្ថានកុងស៊ុល)

_អង្គភាពទំនាក់ទំនងអន្តរជាតិ នៃក្រសួងទាំងពីរ(តាមរយៈទូរស័ព្ទ ទូរសារ អ៊ីមែល) តំណាងសន្តិសុខ ចារកម្មក្រសួងនគរបាលនៅកម្ពុជា

_ការិយាល័យ INTERPOL នៃភាគីនីមួយៗ

_ដោយផ្ទាល់រវាងបណ្តានាយកដ្ឋានជំនាញនៃភាគីទាំងពីរ

_ដោយផ្ទាល់ រវាងនគរបាលបណ្តាខេត្ត ស្រុកដែលមានព្រំដែនរួម

២_ការផ្លាស់ប្តូរបណ្តាក្រុមការងារជំនាញ ដើម្បីដំណើរការសកម្មភាពរួមសហការស៊ើបអង្កេតបណ្តាករណីដែលភាគីទាំងពីរចាប់អារម្មណ៍ត្រូវមានការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួងទាំងពីរ និងត្រូវជូនដំណឹងអោយគ្នាជាលាយលក្ខអក្សរ ។

៣_ភាគីទាំងពីរប្រគល់អោយនគរបាលបណ្តាខេត្តជាប់ព្រំដែន កម្ពុជា_វៀតណាម ប្តូរវេនជួបគ្នា ដើម្បីផ្លាស់ប្តូរពត៌មាន ឯកសារ ពិភាក្សា និងឯកភាពបណ្តាវិធានការសហប្រតិបត្តិការការពារសន្តិសុខ សណ្តាប់ធ្នាប់តំបន់ព្រំដែន បង្ការប្រឆាំងឧក្រិដ្ឋកម្ម ដោះស្រាយបណ្តាករណីដែលកើតមានឡើងនៅតំបន់ព្រំដែន នៃប្រទេសទាំងពីរដោយកំណត់ការជួបគ្នាដូចខាងក្រោម៖

- ថ្នាក់នគរបាលប៉ុស្តិ៍ឃុំជាប់ព្រំដែន : ០១ខែម្តង
- ថ្នាក់នគរបាលស្រុកជាប់ព្រំដែន : ០៣ខែម្តង
- ថ្នាក់នគរបាលខេត្ត-ក្រុងជាប់ព្រំដែន : ០៦ខែម្តង

៤-ភាគីទាំងពីរប្រគល់អោយអង្គភាពទំនាក់ទំនងអន្តរជាតិ នៃភាគីនីមួយៗ ធ្វើការត្រួតពិនិត្យ ក្រើនរំលឹក និងសហការជាមួយបណ្តាអង្គភាពពាក់ព័ន្ធចាត់តាំងអនុវត្តផែនការសហប្រតិបត្តិការដែលបានចុះហត្ថលេខា ។ នៅត្រីមាសទី IV ជារៀងរាល់ឆ្នាំ អង្គភាពទំនាក់ទំនងអន្តរជាតិ នៃក្រសួងទាំងពីរប្តូរវេនជួបគ្នា ដើម្បីពិភាក្សា និងឯកភាព វាយតម្លៃពីលទ្ធផលសហប្រតិបត្តិការ និងពិភាក្សាខ្លឹមសារសហប្រតិបត្តិការសំរាប់ឆ្នាំបន្ត រាយការណ៍ជូនថ្នាក់ដឹកនាំ នៃភាគីទាំងពីរពិនិត្យសំរេច និងរៀបចំការចុះហត្ថលេខា។

៥-ការចំណាយធ្វើដំណើរជាអន្តរជាតិ សំរាប់បណ្តាគណៈប្រតិភូដែលត្រូវចាត់បញ្ជូនអោយទៅបំពេញទស្សនកិច្ច ផ្លាស់ប្តូរបទពិសោធន៍ សិក្សាស្រាវជ្រាវ រៀនសូត្រ ទស្សនកិច្ច សំរាកលំហែកាយ ទំនាក់ទំនងផ្លាស់ប្តូរវប្បធម៌ កីឡា តាមផែនការសហប្រតិបត្តិការនេះ ត្រូវទទួលរ៉ាប់រងដោយភាគីចាត់បញ្ជូន។ ការចំណាយសំរាប់ហូបចុក ស្នាក់នៅ ធ្វើដំណើរក្នុងប្រទេស និងការបង់ពន្ធព្រលានយន្តហោះអន្តរជាតិពេលត្រឡប់ទៅវិញរបស់បណ្តាគណៈប្រតិភូ ដូចបានពោលខាងលើ ត្រូវទទួលរ៉ាប់រងដោយភាគីទទួលគណៈប្រតិភូ លើកលែងតែភាគីទាំងពីរមានការព្រមព្រៀងគ្នាផ្សេងទៀត ។

VII. <u>ប្រសិទ្ធិភាពអនុវត្តន៍</u> :

ផែនការសហប្រតិបត្តិការនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា និងមានតម្លៃរហូតដល់ថ្ងៃចុះហត្ថលេខា ផែនការសហប្រតិបត្តិការឆ្នាំ ២០១២។ ក្នុងករណីភាគីម្ខាងស្នើកែប្រែបំពេញបន្ថែមខ្លឹមសារទៅក្នុងផែនការសហប្រតិបត្តិការនេះ ត្រូវមានការយល់ព្រមជាលាយល័ក្ខអក្សរពីភាគីម្ខាងទៀត ហើយត្រូវជូនដំណឹងអោយគ្នាបានដឹង យ៉ាងតិចបំផុត ០១ខែ មុនពេលអនុវត្ត ។

ផែនការសហប្រតិបត្តិការនេះ ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១១ ជា ០២ច្បាប់ ជាភាសាខ្មែរ និងភាសាវៀតណាម ។ ច្បាប់ទាំងពីរមានតម្លៃស្មើគ្នា ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
នៃព្រះរាជាណាចក្រកម្ពុជា

ស ខេង

រដ្ឋមន្ត្រីក្រសួងនគរបាល
នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ឡេ ហុងអាញ